**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៣៥៩ ព.ណ.ន.ស.

ថ្ងៃ ច័ន្ទ ១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងកសិកម្ម និងសុខុមាលភាពកសិករនៃរដ្ឋាភិបាលឥណ្ឌា បានសម្រេចបន្ធូរបន្ថយលក្ខខណ្ឌតម្រូវនៃការធ្វើធុបទកម្ម (Fumigation) និងការបញ្ជាក់បន្ថែមលើ វិញ្ញាបនប័ត្រភូតគាមអនាម័យ (Phytosanitary Certificate) សម្រាប់ការនាំចេញខ្ទឹមបារាំង ទៅកាន់ប្រទេសឥណ្ឌា រហូតដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២០ ដូចខាងក្រោម៖

១-ចំពោះខ្ទឹមបារាំង ដែលបាននាំចូលមកដល់កំពង់ផែប្រទេសឥណ្ឌា ដោយមិនបានធ្វើធុបទកម្ម និងដោយវិញ្ញាបនបត្រភូតគាមអនាម័យគ្មានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលយក នោះភាគីឥណ្ឌា តម្រូវឱ្យម្ចាស់ទំនិញ ឬអ្នកនាំចូល យកទំនិញនោះ (ខ្ទឹមបារាំង) មកធ្វើធុបទកម្មនៅក្នុងប្រទេសឥណ្ឌា ជាមួយក្រុមហ៊ុនដែលទទួលបានសិទ្ធិផ្តល់សេវាគ្រប់គ្រងសត្វល្អិតនិងធុបទកម្ម។ បន្ទាប់មក ទំនិញ (ខ្ទឹមបារាំង) ទាំងនោះ នឹងត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយមន្ត្រីជំនាញ ហើយអនុញ្ញាតឱ្យនាំចូល ក្នុងករណីដែលពិនិត្យឃើញថាទំនិញ (ខ្ទឹមបារាំង) ទាំងនោះមានសុវត្ថិភាព និងពុំមានជំងឺ មេរោគ ឬសត្វល្អិត។

២-បន្ធូរបន្ថយលក្ខខណ្ឌតម្រូវលើការបញ្ជាក់បន្ថែមលើ វិញ្ញាបនប័ត្រភូតគាមអនាម័យ

៣-កំឡុងពេលត្រួតពិនិត្យ ប្រសិនបើរកឃើញថា ទំនិញ (ខ្ទឹមបារាំង) មានផ្សិត (Smut - Urocystis cepulae) ឬរលួយ (Dry rot - Embellisia allii) នោះទំនិញ ឬកុងតឺន័រទាំងនោះនឹងមិនអនុញ្ញាតឱ្យនាំចូលឡើយ ហើយត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ។

៤-ប្រសិនបើពិនិត្យទៅឃើញថា ទំនិញ (ខ្ទឹមបារាំង) មានបញ្ហា ឬមានជំងឺ Stem and bulbs nematode (Ditylenchus dipsaci) ឬ onion maggot (Hylemia antiqua) ខ្ទឹមបារាំងទាំងនោះនឹងត្រូវបានសម្លាប់មេរោគតាមរយៈការធ្វើធុបទកម្ម ហើយទំនិញទាំងនោះនឹងត្រូវបញ្ចេញដោយមិនគិតថ្លៃអធិការកិច្ចបន្ថែម។

៥-ចំពោះទំនិញ (ខ្ទឹមបារាំង) សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃនឹងមិនតម្រូវឱ្យបង់ថ្លៃត្រួតពិនិត្យបន្ថែម ៤ដង លើការមិនគោរពតាមលក្ខខណ្ឌនៃការនាំចូលស្របតាមច្បាប់ស្តីពី Plant Quarantine Order ឆ្នាំ ២០០៣ របស់ប្រទេសឥណ្ឌាឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ជាផលិតករ ឬអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**សូមអរគុណ!**

ក្រសួងពាណិជ្ជកម្ម